# مدرسة اهل البيت

# សាលា
# អាស់លុល-បៃត៍

## សៀវភៅ អាក់ឡាក់ (أَخْلَاقٌ សីលធម៌)
## ថ្នាក់ទី ១ (អាយុ ៥-៦ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ - សាឡាមុន អ៊ុឡៃគុម (سَلَامٌ عَلَيْكُمْ) និងចម្លើយ........................... ៣

មេរៀនទី ២ ហ្វី អាម៉ានីលឡាស់ (فِي أَمَانِ اللَّهِ) (ឃូដា ហាហ្វីស្ឋ خُدَا حَافِظ)............ ៦

មេរៀនទី ៣ ការចែករំលែក..................................................................... ៨

មេរៀនទី ៤ ធមិមេត្តាចំពោះសត្វ............................................................ ១១

មេរៀនទី ៥ របៀបចូលបង្គន់.................................................................១៣

**មេរៀនទី ១**

# អាស់សាឡាមូ អាឡៃគុម

## (اَلسَّلَامُ عَلَيْكُمْ)

យើងជាមុស្លីម បានសេចក្ដីថាគ្រប់ទង្វើរបស់យើងត្រូវធ្វើដើម្បីអល់ឡោះហ៍ ﷻ ។ អល់ឡោះហ៍ ﷻ បានប្រាប់យើងថាមុស្លីមទាំងអស់ជាបងប្អូនគ្នា ថាយើងត្រូវមើលថែរក្សាគ្នាទៅវិញទៅមក ។

ថា «អាស់សាឡាមូ អាឡៃគុម» មិនមែនមានន័យត្រឹមតែថា "ជម្រាបសួរ ឬ សួស្ដី" ទៅកាន់មនុស្សដូចគ្នានោះទេ តែមានន័យដែរថាយើងយកចិត្តទុកដាក់នឹងអ្នកនោះ យើងបារម្ភអ្នកនោះ យើងមិនប្រព្រឹត្តអាក្រក់ចំពោះអ្នកនោះទេ មិនបៀតបៀនអ្នកនោះទេពីព្រោះ **អាស់សាឡាមូ អាឡៃគុម** មានអត្ថន័យថា "សូមសិរីសួស្ដីកើតមានដល់អ្នក" ។

ពេលអ្នកភ្ញាក់ពីដេក ប្រការដំបូងបង្អស់ដែលអ្នកគប្បីធ្វើគឺថា **អាស់សាឡាមូ អាឡៃគុម** ចំពោះម្ដាយនិងឪពុកអ្នក ។

ពេលមុស្លីមណាបានចូលឋានសួគ៌ ពេលនោះមុស្លីមនោះនឹងបានឮសម្លេងមួយថា **អាស់សាឡាមូ អាឡៃគុម** ដាក់មុស្លីមនោះ ។

ដូច្នេះមុននឹងនិយាយសាសងជាមួយមុស្លីមណាមួយ ចូរថា **អាស់សាឡាមូ អាឡៃគុម** ចំពោះមុស្លីមនោះសិន ។ យកល្អគប្បីចាប់ដៃមុស្លីមនោះរលាក់ (តែចូរប្រយ័តអំពីប្រការ ម៉ាស្រ់ម (مَحْرَم) និង មិន ម៉ាស្រ់ម ។ បុរសនិងស្ត្រីមិនចាប់ដៃគ្នាទេ លើកលែងតែជាបងប្អូនគ្នាបង្កើត) ។

ពេលអ្នកទទួលទូរស័ព្ទ អ្នកត្រូវថា **អាស់សាឡាមូ អ្មាឡៃគុម** ដែរមុនបង្អស់ ។

បើអ្នកណាមួយថា **អាស់សាឡាមូ អ្មាឡៃគុម** មកអ្នក អ្នកត្រូវឆ្លើយអ្នកនោះវិញថា **វ៉ា អ្មាឡៃគុម សាឡាម** (**វ៉ា រ៉ោះហ្មាទុលឡ៉ហ៊្ម វ៉ា បារ៉កាទុះហ្វ** وَ رَحْمَةُ اَللَّهِ وَ بَرَكَاتُهُ) ។ អល់ឡោះហ្វ៍ عز وجل មិនសព្វព្រះហឫទ័យទេដែលគេមិនឆ្លើយតបសាឡាមវិញនោះ ។

**លំហាត់ ១**

ចូរអ្នកថា អាស់សាឡាមូ អាឡៃគុម ទៅមិត្តគ្រប់គ្នានៅក្នុងបន្ទប់រៀនរបស់អ្នក ដោយចាប់ដៃគ្នា ។



ចូរអ្នកចងចាំថា មុស្លីមទាំងអស់គ្នាជាបងប្អូនគ្នា យើងត្រូវស្រឡាញ់គ្នានិងមើលថែរក្សាគ្នាទៅវិញទៅមក ។

**មេរៀនទី ២**

# ហ្វី អាម៉ានីលឡាស់ فِي أَمَانِ اَللَّهِ
# (ឃូដា ហាហ្វីស្ទ خُذَا حَافِظ)

យើងជាមុស្លីម បានសេចក្តីថាគ្រប់ទង្វើរបស់យើងត្រូវធ្វើដើម្បីអល់ឡោះហ្ ﷻ ។ អល់ឡោះហ្ ﷻ បានប្រាប់យើងថាមុស្លីមទាំងអស់ជាបងប្អូនគ្នា ថាយើងត្រូវមើលថែរក្សាគ្នាទៅវិញទៅមក ។

ថា «ហ្វី អាម៉ានីលឡាស់» មិនមែនមានន័យត្រឹមតែថា "ជម្រាបលា ឬ លាហើយ" នោះទេ តែមានន័យដែរថាអ្នកនិយាយចំពោះអ្នកដទៃថាអ្នកស្រឡាញ់អ្នកនោះ អ្នកបារម្ភអ្នកនោះពីព្រោះ ពេលអ្នកថា «ហ្វី អាម៉ានីលឡាស់» អ្នកសូមឲ្យអល់ឡោះហ្ ﷻ មើលថែរក្សាអ្នកនោះ ។

**ហ្វី អាម៉ានីលឡាស់** មានន័យថា "ខ្ញុំសូមផ្ញើអ្នក/លោកក្រោមការការពាររបស់អល់ឡោះហ្ ﷻ" ។
**ឃូដា ហាហ្វីស្ទ** មានន័យថា "សូមអល់ឡោះហ្ ﷻ ថែរក្សាអ្នក/លោក" ។

រាល់ពេលដែលអ្នកចាកចេញពីឪពុកម្តាយ អ្នកត្រូវនិយាយជាមួយលោកថា **ហ្វី អាម៉ានីលឡាស់** ដើម្បីនឹងឲ្យអល់ឡោះហ្ ﷻ ការពារលោក ។

មុននឹងចូលដំណេក ចូរអ្នកថា **ហ្វី អាម៉ានីលឡាស់** ឲ្យឪពុកម្តាយអ្នក ។

## លំហាត់ ២

ចូរផាត់ពណ៌រូបដៃខាងក្រោមនេះដោយថា **ហ្មឺ អាម៉ានីលឡាស់** ។



## មេរៀនទី ៣

# ការចែករំលែក

អល់ឡោះហ៊ ﷻ ទ្រង់សព្វព្រះហឫទ័យ ដែលអ្នកចែករំលែករបស់របរអ្នកឲ្យអ្នកដទៃប្រើប្រាស់ផង ។ ចូរអ្នកកុំភ្លេចថាអ្វីៗដែលអ្នកមានបាននោះមកពីអល់ឡោះហ៊ ﷻ ។ ដើម្បីអរព្រះគុណព្រះអង្គ ﷻ ដែលអ្នកមានបាននោះ អ្នកត្រូវស្តាប់ព្រះអង្គ ﷻ ។

ថ្ងៃមួយ មានស្ត្រីម្នាក់មកលេងម្តាយត៏លិប ។ គាត់បាននាំក្មេងប្រុសតូចម្នាក់មកផង ។ ម្តាយត៏លិបបានប្រាប់ត៏លិបឲ្យលេងជាមួយក្មេងតូចនោះ ។ ត៏លិបមិនចង់ឲ្យក្មេងតូចនោះលេងជាមួយរបស់លេងវាទេ វាខ្លាចក្មេងនោះធ្វើឲ្យរបស់លេងនោះខូច ។ ក្មេងតូចនោះយំប្រាប់ម្តាយវា ។ ម្តាយត៏លិបឲ្យត៏លិបចែករបស់លេងជាមួយក្មេងតូចនោះ តែត៏លិបមិនព្រមទេ ។
ក្រោយពីនោះពីរបីថ្ងៃ ត៏លិបបានទៅលេងផ្ទះមិត្តវាម្នាក់ តែមិត្តវាកាច មិនឲ្យត៏លិបលេងជាមួយរបស់លេងវាទេ ។ ត៏លិបតូចចិត្ត ។

ពេលត្រឡប់មកផ្ទះវិញ ត៏លិបនិយាយប្រាប់ម្តាយថាមិត្តវាកាច ។ ម្តាយត៏លិបបានសួរត៏លិបថាតើវាមានអារម្មណ៍យ៉ាងណាពេលមិត្តវាកាចដាក់វា មិនព្រមឲ្យវាខ្ចីគ្រឿងលេងរបស់វា ។ ត៏លិបថាវាតូចចិត្ត ។ ពេលនោះម្តាយត៏លិបរំលឹកត៏លិបថាវាក៏កាចដាក់ក្មេងតូចនោះដែរដែលបានមកលេងផ្ទះវាថ្ងៃមុននោះ កាលវាមិនព្រមឲ្យក្មេងតូចនោះលេងជាមួយគ្រឿងលេងរបស់វា ។

ត៏លិបសោកស្តាយណាស់ដែលមិនបានចែករបស់លេង ដែលបានធ្វើឲ្យក្មេងតូចនោះតូចចិត្ត ។ ត៏លិបបានសន្យាថានឹងចែកអ្វីៗសព្វគ្រប់ជាមួយអ្នកដទៃអំណឹះតទៅ

ដើម្បីសម្តែងឲ្យឃើញថាវាស្តាយក្រោយជាទីបំផុត ដែលបានប្រព្រឹត្តមិនគប្បីនោះ

ក៏លិបបានសូមទោសក្មេងតូចនោះពេលវាមកលេងផ្ទះវាម្តងទៀត ក៏លិបបើកដៃឲ្យក្មេងតូចនោះលេងតាមចិត្ត ។

ឧត្តមគតិរឿងនេះគឺ អ្នកត្រូវចែករំលែកអ្វីដែលអ្នកមាន ត្រូវបំពេញតម្រូវការអ្នកដទៃ ។

ចូរអ្នកចងចាំថា អល់ឡោះហ៍ﷻប្រទានឲ្យអ្នកនូវអ្វីៗដែលអ្នកមានបាន ។ ពេលអ្នកប្រព្រឹត្តដើម្បីផ្គាប់ផ្គុនអល់ឡោះហ៍ﷻ អល់ឡោះហ៍ﷻនឹងប្រទានឲ្យអ្នកកាន់តែច្រើនឡើងៗ ។

**លំហាត់ ៣**

# ការចែករំលែក

ត៏លិបមានការេមមួយដើម តើវាត្រូវធ្វើអ្វី ? ចូរផាត់ព័ណ៌រូបខាងក្រោមនេះ ។



**មេរៀនទី ៤**

# ធម៌មេត្តាចំពោះសត្វ

ត៍្កលិបកំពុងដើរជាមួយម្ដាយស្រាប់តែឃើញស្រមោចវារនៅលើដី ។ វាក៏ជាន់ស្រមោចនោះ ។ ម្ដាយត៍្កលិបឃើញកូនធ្វើដូច្នេះក៏មានទោមនស្ស ។ គាត់បានប្រាប់ត៍្កលិបថាសត្វទាំងអស់ជាសត្វលោករបស់អល់ឡោះហ្វ៍عز وجل ដូចវាដែរ ។ បន្ទាប់មកគាត់បាននិយាយរឿងមួយ ដែលព្រះសាស្ដាមូហាំម៉ាដ្ឋ៍ﷺបាននិយាយប្រាប់មុស្លីមថា៖

"មានបុរសម្នាក់ដើរក្នុងវាលខ្សាច់ ។ ថ្ងៃក្ដៅណាស់ គាត់ស្រេកទឹកស្ទើរស្លាប់ ។ គាត់ដើររកទឹកលុះបានឃើញអណ្ដូងទឹកមួយ ។ គាត់ចុះទៅក្នុងអណ្ដូងទឹកនោះយ៉ាងលំបាកលុះបានទៅដល់ទឹក ។ គាត់បានផឹកទឹកទាល់តែឆ្អែត រួចរាល់ហើយគាត់ឡើងពីក្នុងអណ្ដូងវិញ ។ នៅខាងលើមាត់អណ្ដូងគាត់ឃើញឆ្កែមួយអណ្ដាតធ្លាក់ វាស្រេកទឹកខ្លាំងណាស់ ។ បុរសនេះនឹកឃើញកាលខ្លួនគាត់ស្រេកទឹកខ្លាំងកាលពីមុននេះបន្ដិច ។ ហេតុដូច្នេះគាត់ក៏សម្រេចចិត្តចុះទៅក្នុងអណ្ដូងទឹកវិញដើម្បីយកទឹកមកឲ្យឆ្កែផឹក ។ មិនមានអ្វីសម្រាប់ដាក់ទឹកទេ ។ ដូច្នេះ លុះគាត់បានចុះទៅដល់បាតអណ្ដូង គាត់ក៏បានយកស្បែកជើងឃ្លុបរបស់គាត់ដួសទឹកពេញ ។ គាត់ឡើងពីក្នុងអណ្ដូងវិញដោយពាំស្បែកជើងឃ្លុបនឹងមាត់ ពីព្រោះគាត់ត្រូវប្រើដៃគាត់សម្រាប់តោងឡើងពីក្នុងអណ្ដូង ។ គាត់ពិបាកឡើងនិងនឿយហត់ណាស់មុននឹងបានឡើងដល់លើមាត់អណ្ដូង ។ ឆ្កែរីករាយណាស់ពេលឃើញទឹក វាបក់កន្ទុយយ៉ាងតក់ក្រហល់ ។ វាបានផឹកទឹកក្នុងស្បែកជើងមួយហើយមួយទៀត ។ បុរសនោះបានបន្តដំណើរទៅមុខទៀតដោយរីករាយ ។ ព្រះសាស្ដាﷺមានព្រះវចនៈថា អល់ឡោះហ្វ៍عز وجلទ្រង់សព្វព្រះហឫទ័យបុរសនោះណាស់ គាត់នឹងបានចូលឋានសួគ៌ ។"

ពេលត៍្កលិបបានស្ដាប់ម្ដាយនិយាយរឿងនេះចប់ វាក៏ស្ដាយក្រោយដែលបានជាន់ស្រមោចនោះ ។ ត៍្កលិបសន្យាថានឹងអាណិតអាសូរសត្វអំណឹះតទៅ ព្រោះត៍្កលិបចង់ចូលឋានសួគ៌ដែរ ។ (រាយការណ៍តមកពីអ៊ីមុាំ អាល់-ហ្វាសាន់صلوات الله عليه والسلام)

**លំហាត់ ៤**

# ធម៌មេត្តាចំពោះសត្វ

ចូរអ្នកនិយាយរឿងឆ្កែស្រែកទឹកឲ្យឪពុកម្ដាយស្ដាប់ ។



ចូរផាត់ពណ៌រូបឆ្កែ ។

**មេរៀនទី ៥**

# របៀបចូលបង្គន់

ពេលណាអ្នកចង់បត់ជើងតូចឬបត់ជើងធំ អ្នកត្រូវតែចូលបង្គន់ភ្លាម កុំបង្អែបង្អង់យូរ កុំចាំឲ្យរួចរាល់ពីការងារសិននោះទេ ។

មុននឹងចូលបង្គន់ អ្នកត្រូវពាក់ស្បែកជើង ព្រោះផ្ទៃដីអាចទទឹក (ណាយ៉ីស) ជើងអ្នកអាចនឹងទទឹកដែរ (ទៅជាណាយ៉ីសដែរ) ។

ពេលអ្នកចូលបង្គន់ អ្នកត្រូវឈានជើងឆ្វេងចូលមុន ។

យកទឹកដោយបោយឬធុង (បើអ្នកអាចលាងសម្អាតដោយខ្លួនឯងបាន) ។

ពេលអ្នកចូលបង្គន់នៅឯសាលារៀន អ្នកត្រូវព្យាយាមយកទឹកតាមខ្លួនក្នុងកាទឹក ។

បើមិនមានទឹកលាងទេ អ្នកត្រូវជូតដោយក្រដាសក្រោយពីបានបត់ជើងតូចរួច ។

ចូរអ្នកកុំភ្លេចប្រាប់ម្តាយអ្នកថាអ្នកបានជូត មិនបានលាងទឹកទេ ដើម្បីនឹងឲ្យគាត់ដឹងថាខោទ្រនាប់អ្នកអាចណាយ៉ីសដែរ ហើយត្រូវការបោកជម្រះណាយ៉ីស ។

ពេលអ្នកចូលបង្គន់ ចូរអ្នកអង្គុយលើកន្លែងអង្គុយ ។ អល់ឡោះហ្ទ៉ាﷻមិនសព្វព្រះហឫទ័យអ្នកណាបត់ជើងតូចឈរទេ ។

ពេលអ្នកបត់ជើងតូចរួច ចូរអ្នកលាង ២ ដង ឬ ៣ ដងបើអាចធ្វើបាន ។ បើមិនអាចធ្វើបានទេ ចូរហៅគេឲ្យលាងឲ្យអ្នក ។

រួចរាល់ហើយ ចូរងើបឡើង ហើយស្លៀកពាក់វិញ ។

ចូរទាញខ្សែ ឬ សង្កត់ប្រដាប់ចាក់ទឹកបង្គន់ ។ រួចហើយចូរលាងដៃ ហើយជូតដៃឲ្យស្ងួត ។

ចេញពីបង្គន់ដោយឈានជើងស្តាំមុន ។

ចូរចងចាំថា ពេលអ្នកអង្គុយក្នុងបង្គន់ ចូរកុំបែរមុខទៅរកគិ្លបឡាត់ ។

បើបង្គន់បែរមុខទៅរកគិ្លបឡាត់ អ្នកត្រូវអង្គុយបញ្ចៀងខ្លួនទៅខាងបន្តិច ។ ចូរកុំនិយាយនៅក្នុងបង្គន់ ។

**លំហាត់ ៥**

# របៀបចូលបង្គន់

ចូរដាក់លេខរៀងលើរូបភាពឲ្យត្រូវតាមលំដាប់ ។







